**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ : ០៣២ ដនស/ប្រក/និ.ក

# ប្រកាស
# ស្តីពី
# ការកំណត់ជាឧត្តមប្រើថពីទិតាគផ្ទៃរាបនៃព្រះរាជាណាចក្រកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ ស្តីពីការបង្កើតនាយកដ្ឋាន បច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី



អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ១១២០ អនក្រ.បក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានសម្បទានដីសង្គមកិច្ចចំណុះអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- យោងតម្រូវការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ ._**

ប្រកាសនេះកំណត់អំពីដាតទុមប្រឹថពីវិភាគផ្ទៃរាបនៃព្រះរាជាណាចក្រកម្ពុជា ២០២៣ (Cambodia Geodetic Datum 2023 - CGD23) ក្នុងគោលបំណងធានាការប្រើប្រាស់ឱ្យមានការឯកភាពគ្នាទូទាំងប្រទេស ក្នុងការវាស់វែង និងការផលិតផែនទីគ្រប់ប្រភេទ។

**ប្រការ ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តលើផ្ទៃដីទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ដាតទុមប្រឹថពីវិភាគផ្ទៃរាបនិងចំណុចដាតទុម CGD23 គោល

**ប្រការ ៣ ._**

ដាតទុមប្រឹថពីវិភាគផ្ទៃរាបនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម÷

- ឈ្មោះ (Name): Cambodia Geodetic Datum 2023 (CGD23)
- បណ្តាញយោង (Reference Frame): International Terrestrial Reference Frame2020 (ITRF2020)
- ពេលវេលានៃការវាស់វែង (Epoch): 2023.355
- អេលីបសូអ៊ីដ (Ellipsoid): Geodetic Reference System 1980 (GRS 80)
- ពាក់កណ្តាលអ័ក្សធំ (Semi-major Axis): a=6 378 137.0 meter
- ភាពសំប៉ែត (Flattening): 1/f = 1/298.257222101
- ចំណោលផែនទី (Projection ): UTM Zone 48 North

**ប្រការ ៤ ._**

ចំណុចដាតទុម CGD23 គោល ត្រូវបានកំណត់ដូចខាងក្រោម÷

- ឈ្មោះស្ថានីយ : PNH100KHM
  - រយៈទទឹង : N11° 37’ 47.13795”
  - រយៈបណ្តោយ : E104° 52’ 20.72324’’
  - កម្ពស់អេលីបសូអ៊ីដ : 2.735 meter

- កាលបរិច្ឆេទវាស់វែង : 10 ឧសភា 2023
- ទីតាំងស្ថានីយ : រាជធានីភ្នំពេញ

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**ប្រការ ៥ ._**

អ្នកវាស់វែង និងក្រុមហ៊ុនវាស់វែងទាំងអស់ ត្រូវប្រើប្រាស់ដាតទុមCGD23 ចាប់ពីថ្ងៃដាក់ឱ្យអនុវត្តប្រកាសនេះ។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវបំប្លែងរាល់ទិន្នន័យវាស់វែងគោល និងទិន្នន័យផែនទីគោលទាំងអស់ មកជាទិន្នន័យតាមដាតទុម CGD23។

វិធីសាស្ត្រប្រើប្រាស់ដាតទុម CGD23 ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ។

**ប្រការ ៦ ._**

ក្រោយចុះហត្ថលេខា ប្រកាសនេះត្រូវផ្សព្វផ្សាយក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ទើបត្រូវអនុវត្ត។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨ ._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល ÷**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -រដ្ឋបាលរាជធានី ខេត្ត
- -ដូចមានក្នុងប្រការ៨
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ